# ចម្លាក់ព្រះសិវៈទំរង់ជាកិរត និងអជ៌ុនក្នុងសិល្បៈខ្មែរ

***Kirātārjunīya Iconography***

ចម្លាក់ព្រះសិវៈទំរង់ជា**កិរត** ប្រយុទ្ធជាមួយ**អជ៌ុន**ពុំសូវមានឆ្លាក់ច្រើនទេទាំងចម្លាក់លើផ្តែរ ជញ្ជាំង និងចម្លាក់ទោល។ ទាំងសម័យមុនអង្គរ រហូតដល់សម័យអង្គរពុំដែលមានចម្លាក់ បង្ហាញរឿងជា**កិរត** និង**អជ៌ុន**ប្រយុទ្ធគ្នានោះទេ។ ប៉ុន្តែក្នុងរាជព្រះបាទជ័យវរ្ម័នទី៤ ចាប់ផ្តើមបង្ហាញរឿងទេវកថាច្រើន និងច្បាស់លាស់តាមព្រហ្មញ្ញសាសនា។ ចម្លាក់នៅកោះកេរ មានរឿងទេវកថាច្រើនផ្សេងៗគ្នា ដូចជារឿងរាមកេរ្តិ៍ មហាភរត គម្ពីសិវៈនិកាយ និងវិស្ណុនិកាយជាដើម។ រហូតមកដល់រចនាបថកោះកេរនេះចម្លាក់ និងសិល្បៈបានបង្ហាញការវិវត្តន៍ថ្មីជាងសម័យមុនៗ និងបង្ហាញស្នាដៃដ៏អស្ចារ្យ មិនថាតែសំណង់ស្ថាបត្យកម្មការរៀបចំក្រុងនោះទេ តែស្នាដៃចម្លាក់ និងសិល្បៈផងដែរ។ អត្ថបទនេះនឹងបង្ហាញ និងចម្លាក់**កិរត** និង**អជ៌ុន**ប្រយុទ្ធគ្នានៅក្នុងសិល្បៈខ្មែរ និងធ្វើការប្រៀបធៀបទេវកថាបុរាណ និងចម្លាក់មួយចំនួននៅឥណ្ឌាខាងត្បូង ព្រមទាំងបង្ហាញប្រវត្តិរឿង**កិរត** និង**អជ៌ុន** ក្នុងទេវកថា និងមហាភរតតិចតួច។

ព្រះសិវៈទំរង់ជា**កិរត** និង**អជ៌ុន**មានឈ្មោះម្យ៉ាងទៀតហៅថា**កិរាតាជ៌ុនីយ** ដែលមានជាចម្លាក់ទោល នៅប្រាកទី២ផ្នែកខាងលិចប្រាសាទរួម (ប្រាសាទធំ) និងជាចម្លាក់លើផ្តែរ ហោជាង និងជញ្ជាំងប្រាសាទមួយចំនួនទៀតនៅក្នុងតំបន់អង្គរ។ ចម្លាក់ទោល**កិរិតអជ៌ុន** បង្ហាញតំបូងក្នុងស.វទី១០គ.ស រហូតដល់ស.វទី១៣គ.ស។ ប៉ុន្តែចម្លាក់មួយនៅប្រាសាទ *Kailasanathar* ឥណ្ឌាខាងត្បូងមាន ចម្លាក់**កិរត** និង**អជ៌ុន**ប្រយុទ្ធគ្នាធំមួយនៅលើជញ្ជាំងនៅស.វទី៧ និងទី៨គ.ស(រូបលេខ១)។ ចម្លាក់ទោលនៅប្រាសាទធំកោះកេរ និងចម្លាក់លើផ្តែរ ឬហោងជាងតំបន់អង្គរ គឺខុសពីចម្លាក់នៅប្រទេសឥណ្ឌា ដែលឆ្លាក់នៅលើតែជញ្ជាំង និងថ្មភ្នំធម្មជាតិប៉ុណ្ណោះ។ ទោះបីចម្លាក់ប្រភេទនេះ សំបូរបែបនៅប្រទេសឥណ្ឌាក៏ដោយ ប៉ុន្តែចម្លាក់នៅខ្មែរវិញ បង្ហាញតែនៅលើសំណង់ប្រាសាទ និងមួយជាចម្លាក់ទោលប៉ុណ្ណោះ។

អត្ថបទដោយ៖ ជូ ជុន

## កិរាតាជុំនីយក្នុងទេវកថា និងមហាភរត

ទេវកថា**កិរិត** និង**អជ៌ុន** មាននៅក្នុងមហាភរត មានអាយុកាលចាប់ពីចុងស.វទី៤មុន គ.ស (ជំពូកទី១៦៧) និងមានបង្ហាញច្បាស់ក្នុងអត្ថបទជាសំស្ក្រឹត ដែលរឿងទាក់ទងទៅនឹងដើមកំណើតប្រពៃណីពីសម័យបុរាណ។[១] រឿង**កិរាតាជុំនីយ**ពេញនិយមក្នុងអត្ថបទជាភាសាសំស្ក្រឹត នៅសតវត្សទី៦គ.សនៅប្រទេសឥណ្ឌា។[២] រឿងនេះនិយាយពីការប្រយុទ្ធគ្នារវាងអជ៌ុន និងព្រះសិវៈទំរង់ជាកិរតនៅលើកំពូលភ្នំមួយ។ ដោយកិរត គឺជាអ្នកការពារព្រៃអ្នករស់នៅលើភ្នំ និងជាកុលសម្ព័ន្ធបុរេប្រវត្តិដើមមួយរបស់ហិណ្ឌូស ដែលដំណើរគ្នានឹងរឿងមហាភរតដែរ។[៣]

បន្ទាប់ពីបិសាចមួយឈ្មោះមុកាសុរៈ បានប្រែក្រឡាទំរង់ជាសត្វជ្រូកព្រៃមួយ។ ព្រះសិវៈបង្ហាញជាទំរង់កិរត ដែលជាអ្នកឡើងភ្នំ និងប្រមាញ់សត្វ។ ដំណាលរឿងពេលព្រះសិវៈសាកល្បងជាមួយអជ៌ុន គ្រប់រូបភាពអស់ហើយ ទើបទ្រង់សម្រេចតតាំងជាមួយអជ៌ុន។ ព្រះសិវៈបានតាមមករកជ្រូកព្រៃទម្រង់ជាកិរត ដែលអមដោយព្រះព្រហ្ម ព្រះស្កន្ទ និងវិស្ណុក្នុងទម្រង់អ្នកប្រមាញ់ផង ដើម្បីតាមប្រមាញ់ជ្រូកព្រៃនោះ។[៤]

**កិរត** និង**អជ៌ុន**បាញ់ព្រួញសម្លាប់ជ្រូកនោះ ហើយពួកគេបានប្រកែកគ្នាដណ្ដើមថាខ្លួនជាអ្នកបាញ់ បន្ទាប់មកការប្រយុទ្ធក៏កើតមានឡើង។ ពួកគេប្រយុទ្ធអស់រយៈពេលជាយូរ ហើយអជ៌ុនមានការភ្ញាក់ផ្អើល ដែលគាត់មិនអាចយកឈ្នះកិរតបាន។ ការប្រយុទ្ធនេះបង្កើតបានក្មេង និងផ្សេង ហើយអជ៌ុនមានអារម្មណ៍ថាចុះខ្សោយកំលាំង។ ប៉ុន្តែនៅពេលប្រយុទ្ធអជ៌ុន ឃើញកម្រងផ្កា ដែលគាត់បានថ្វាយចំពោះព្រះសិវៈ នៅលើព្រះកេសកិរត បន្ទាប់មកគាត់ស្គាល់ថាជាព្រះសិវៈ ក៏ចុះចាញ់ប្រគល់ខ្លួនឱ្យកិរត។[៥] ព្រះសិវៈរីករាយនឹង

[១] Rajarajan, 2012: 355

[២] Singh, 2002

[៣] Arthur A, 1979: 240

[៤] Raju, 2021: 360

[៥] Roveda, 2003: 159

ភាពក្លាហានរបស់គាត់ និងផ្តល់ឱ្យគាត់នូវអាវុធដ៏មានឥទ្ធិពល គឺបាគុបតាស្ត្រ (*pāśupatāstra*) ឱ្យ**អជ៌ុន** ដែលក្រៅពី**អជ៌ុន**គ្មានអ្នកណាកាន់លើកវាបានទេនៅក្នុងរឿងមហាភារត។[៦] កំឡុងពេលនោះ ព្រះឥន្ទ្រ ព្រះភិរុណ ព្រះយម និងព្រះគុពេរ ក៏បាននាំគ្នាសាកល្បងភាពក្លាហាន **អជ៌ុន** ដើម្បីផ្តល់អាវុធឱ្យគាត់ផងដែរ។[៧]

## ចម្លាក់កិរត និងអជ៌ុន

បដិមាបង្ហាញរឿងការប្រយុទ្ធគ្នារវាង**កិរត** និង**អជ៌ុន**ជាចម្លាក់ទោលសំខាន់មួយនៅច្រកចូលទី២ផ្នែកខាងលិចប្រាសាទធំកោះកេរ គឺជាចម្លាក់ទោលតែមួយ។ ការបង្ហាញខ្លួនមនុស្ស២នាក់ប្រយុទ្ធគ្នាហៅថា**កិរាតាជ៌ុនីយ** ឆ្លាក់នៅលើជើងទម្រតែមួយ ជាចម្លាក់ដែលធំ និងមានតែមួយនៅស្រុកខ្មែរ។ ក្នុងរឿងនេះដែលអ្នកស្រាវជ្រាវគិតថា ជាការប្រយុទ្ធក្នុងរឿងព្រះសិវៈទម្រង់ជាកិរតជាអ្នកប្រមាញ់ និងអជ៌ុន។ រឿងនេះបង្ហាញពីព្រះសិវៈទម្រង់ជាកិរតជាព្រានព្រៃបរបាញ់សត្វ និងអជ៌ុន ដែលមានកំពស់ប្រហែល៨០សង់ទីម៉ែត្រ និងមានទីតាំងនៅប្រាសាទធំ (រូបលេខ២)។ ចម្លាក់នៅប្រាសាទរួមនេះគឺ ជាចម្លាក់ទោលកិរត និងអជ៌ុន ប្រយុទ្ធគ្នានៅច្រកចូលទី២ប្រាសាទរួមកោះកេរ ដែលមានទំហំធំជាងគេ និងក្បាច់ឆ្លាក់ល្អជាងនៅតំបន់អង្គរ។ ប៉ុន្តែចម្លាក់ផ្តែរប្រាសាទបន្ទាយស្រី កិរតប្រយុទ្ធជាមួយអជ៌ុន យើងឃើញមានឆ្លាក់ទម្រង់ឈរអោបគ្នា មិនសូវបង្ហាញដូចជាការប្រយុទ្ធគ្នា ដូចចម្លាក់នៅឥណ្ឌា និងកោះកេរទេ។ ចម្លាក់លើផ្តែរនេះបង្ហាញរូបកិរត និងអជ៌ុនផុសចេញពីអ័ក្សជាផ្កាភ្ញី ហើយដៃម្ខាងអោបចង្កេះគ្នាវិញ(រូបលេខ៣)។ ចម្លាក់កិរត និងអជ៌ុនផ្សេងទៀត គឺឆ្លាក់លើផ្តែរប្រាសាទព្រះវិហារក្នុងស.វទី១២គ.ស ដែលបង្ហាញកាយវិការស្រដៀងប្រាសាទបន្ទាយស្រីដែរ(រូបលេខ៤)។

KHMER CIVILIZATION

[៦] Marguerite, 1971: 31; Banerji. S.C, 1989 & Vettam, 1996: 412

[៧] Michael, 2001:7




***រូបលេខ១៖*** *កិរតប្រយុទ្ធជាមួយអជ៉ុន នៅប្រាសាទ* Kailasanathar, Kanchipuram, *ស.វទី៧គ.ស*



***រូបលេខ២៖*** *ចម្លាក់កិរតប្រយុទ្ធជាមួយអជ៉ុន នៅច្រកចូលទៅ២ ប្រាសាទរួមកោះកេរ(ប្រភព៖*EFEO)



***រូបលេខ៣៖*** *ចម្លាក់កិរត និងអជ៉ុន នៅផ្តែរប្រាសាទ បន្ទាយស្រី នៅចុងស.វទី១០គ.ស*



***រូបលេខ៤៖*** *ចម្លាក់កិរត និងអជ៉ុនប្រយុទ្ធគ្នា នៅ ប្រាសាទព្រះវិហារ នៅស.វទី១២គ.ស*

ចម្លាក់សំខាន់ផ្សេង១ទៀតនៅប្រាសាទបាពួន គឺបង្ហាញទម្រង់**កិរត** និង**អជ៉ុន**ជាសាច់រឿងទៅតាមដំណាក់កាលនីមួយៗ មាន៤ផ្នែករាប់ពីលើចុះក្រោម ស្ថិតនៅខ្លោងទ្វារទី២ ខាងកើត។ ផ្នែកទី១ បង្ហាញពីអជ៉ុនគោរពបូជាព្រះសិវៈដោយធ្វើតបៈ ផ្នែកទី២ អជ៉ុនទទួលពរ និងអាវុធពីព្រះសិវៈ ផ្នែកទី៣ កិរត និងអជ៉ុនដណ្តើម និងឈ្លោះគ្នាបាញ់ជ្រូកព្រៃ និងផ្នែកទី៤ បង្ហាញកិរត និងអជ៉ុនប្រយុទ្ធគ្នា(រូបលេខ៥)។ ត្រង់ចម្លាក់នៅប្រាសាទបាពួននេះ នៅក្នុងស.វទី១១គ.ស គឺបង្ហាញជារឿងច្បាស់តាមគម្ពីសិវៈបុរាណ ដែលមិនឃើញមានធ្លាក់បង្ហាញទេនៅខ្មែរ។ ប៉ុន្តែចម្លាក់នៅប្រាសាទបាពួននេះ បង្ហាញស្រដៀងគ្នានឹងប្រាសាទ(*Brhadivara*) សម័យCola ក្នុងស.វទី១០គ.ស (រូបលេខ៦-៧)។ ចម្លាក់ទាំងពីរនេះ

អត្ថបទដោយ៖ **ថូ ថុន**

បង្ហាញស្រដៀងគ្នាច្រើនតាមសាច់រឿងក្នុងគម្ពីរវេទ។ ជាពិសេសចម្លាក់បង្ហាញការគោរពបូជា ការបាញ់ជ្រូកព្រៃ និងបង្ហាញរូបសត្វព្រៃ គឺស្រដៀងគ្នា។ ប៉ុន្តែនៅឥណ្ឌាមានបង្ហាញ



**រូបលេខ៥៖** កិរាត និងអជុំនជាបន្តបន្ទាប់មាន៤វគ្គ នៅប្រាសាទបាពួន នៅស.វទី១១គ.ស





**រូបលេខ៦៖ កិរាត** និង**អជុំន** បង្ហាញបន្តបន្ទាប់៥វគ្គ នៅប្រាសាទBrhadisvara។ **រូបលេខ៧៖** រឿងជាបន្តបន្ទាប់៤វគ្គ នៅ (*Brhadivara*) សម័យCola, ស.វទី១០គ.ស (Rajarajan, 2012 )

ការធ្វើតបៈឈរជើងម្ខាងរបស់**អជុំន** និងឆ្លាក់បង្ហាញទេពផ្សេងៗចូលរួមច្រើន ខុសពីនៅប្រាសាទបាពួនគឺ បង្ហាញត្រង់លើអាវុធប្រយុទ្ធគ្នា។

ចម្លាក់**កិរាត** និង**អជុំន**ផ្សេងទៀតនៅលើហោជាង ប្រាសាទបន្ទាយអំពិល នៅសល់តែរូបជ្រូកព្រៃ ហើយកិរាត និងអជុំនសង្ខាងខូចខាតខ្លាំងស្ទើរមើលមិនដឹង (រូបលេខ៨)។ ផ្តែរនៅប្រាសាទ*Prang Hin Daeng* ជាតួប៉មបន្ថែមជាមួយប្រាសាទភីមៃ នៅចុងស.វទី១២ និង១៣គ.ស គឺបានបង្ហាញឈុតបាញ់ជ្រូកព្រៃដូចគ្នា នៅតំបន់អង្គរដែរ។ ចំណែកនៅព្រះខ័នមានចម្លាក់អជុំន និងកិរាតនៅលើចម្លាក់ តូចៗនៅចន្លោះបង្អួចផ្នែកខាងលិចខ្លោងទ្វារទី៣។ ចម្លាក់នៅព្រះខ័នបង្ហាញជ្រូកព្រៃនៅកណ្តាលលើក្បាលរាហូ មានដុះចេញផ្កាឈូកមានទេពអង្គុយសមាធិកនៅខាងលើ[8] និងបង្ហាញកិរាតជាមួយអជុំនបាញ់ព្រួញ (រូបលេខ៩)។ ចម្លាក់បាញ់ជ្រូកព្រៃដូច្នេះ គឺមិនត្រឹមតែបង្ហាញក្នុងសិល្បៈខ្មែរប៉ុណ្ណោះទេ ប៉ុន្តែបង្ហាញផងដែរនៅ*Calukya*ប្រទេសឥណ្ឌា តាំងពីស.ទី៧គ.សមក(រូបលេខ១០-១១)។ ជាពិសេសចម្លាក់នៅ*Calukya* ប្រទេសឥណ្ឌា គឺមានបន្ថែមការធ្វើតបៈរបស់**អជុំន** នៅផ្នែកខាងឆ្វេង។

[8] រូបអង្គុយសមាធិកនេះ គឺស្រដៀងរូបព្រះសិវៈអង្គុយលើអសនៈ និងមានអ្នកគោរពបូជាដូចរូបខាងក្រោម។



*រូបលេខ៨៖ ចម្លាក់កិរតអជ៌ុន ដែលមានជ្រូកព្រៃនៅកណ្ដាល, ប្រាសាទបន្ទាយអំពិល ស.វទី១២គ.ស*



*រូបលេខ៩៖ ចម្លាក់កិរតអជ៌ុន ដែលមានជ្រូកព្រៃនៅកណ្ដាល នៅលើចម្លាក់តូច, ប្រាសាទព្រះខ័ន ស.វទី១២, ១៣គ.ស*



*រូបលេខ១០៖ ចម្លាក់កិរតអជ៌ុន មានជ្រូកព្រៃនៅកណ្ដាល និងអជ៌ុនធ្វើតបៈនៅខាងឆ្វេង, ផ្នែកខាងលិចប្រាសាទ Calukya, ស.វទី៧គ.ស*



*រូបលេខ១១៖ កិរតអជ៌ុន ជ្រូកព្រៃនៅកណ្ដាលឈរលើមនុស្ស, ផ្នែកខាងលិចប្រាសាទ Calukya, ស.វទី៧គ.ស*

ចម្លាក់**កិរត** និង**អជ៌ុន**នៅលើជញ្ជាំងខាងក្នុងប្រាសាទបាយ័ន ចម្លាក់រឿង គឺពិបាកមើលដោយសារចម្លាក់ ធ្លាក់មិនសូវច្បាស់នៅលើជញ្ជាំង(រូបលេខ១២)។ កិរត និងអជ៌ុន គឺបង្ហាញនៅផ្នែកខាងក្រោម ប៉ុន្តែនៅខាងលើបង្ហាញព្រះសិវៈអង្គុយលើបល្ល័ង្ក។ **កិរិត**នេះបង្ហាញជារូប ដែលមានមួកចំឡែក ដូចជាស្លឹកឈើទៅវិញ។[៩] ប៉ុន្តែចម្លាក់នៅជញ្ជាំងប្រាសាទបាយ័ននៅស.វទី១៣គ.ស គឺជាចម្លាក់ពេញជាមួយរូបព្រះសិវៈអង្គុយលើបល្ល័ង្ក និងមានអ្នកគោរពបូជាសង្ខាង ដែលស្រដៀងគ្នានឹងចម្លាក់នៅប្រាសាទHoyasalesvaraក្នុងឥណ្ឌា នៅស.វទី១២គ.សដែរ(រូបលេខ១៣)។ ចម្លាក់នៅឥណ្ឌាបង្ហាញព្រះសិវៈនៅផ្នែកខាងឆ្វេង តែនៅប្រាសាទបាយ័នព្រះសិវៈគង់នៅផ្នែកខាងលើ។

៩ Rovenda, 2003: 162



**រូបលេខ១១២៖** ចម្លាក់រឿងកិរតអជុន ជាមួយព្រះសិវៈគង់លើបល្ល័ង្គ និងមានរូបអជុន ឬព្រាហ្មណ៍គោរពបូជា នៅលើជញ្ជាំងប្រាសាទបាយ័ន ស.វទី១៣គ.ស



**រូបលេខ១១៣៖** ចម្លាក់រឿងកិរតអជុន ជាមួយព្រះសិវៈគង់លើបល្ល័ង្គ និងមានរូបអជុន ឬព្រាហ្មណ៍គោរពបូជា នៅលើចម្លាក់តូចៗ, ប្រាសាទ*Hoyasalesvara*ក្នុងប្រទេសឥណ្ឌា នៅស.វទី១២គ.ស (Raju, 2012: 364)

KHMER CIVILIZATION

## ឯកសារយោង

**1-Arthur A. MacDonnell, (1979).**

A History of Sanskrit Literature, Delhi: Motilal Banarsidass, pp. 240.

**2-Banerji, S. C. (1989).**

*A Companion to Sanskrit literature: Spanning a period of over three thousans years, containing brief accounts of authors, works, characters, technical terms, geographical names, myths, legends and several appendices* (2nd ed.). Delhi: Motilal Banarsidass.

**3- Marguerite E. Adicéam, (1971).**

"Les images de Śiva dans l'inde du sud, Pāśupatamūrti", *Arts Asiatiques*:24, pp. 31.

**4- Michael D. Rabe, (2001).**

*The Great Penance at Māmallapuram. Deciphering a Visual Text*, Institute of Asian Studies, pp. 7.

**5-Rajarajan, R.K.K. (2012).**

"*From Purāṇic to Folk: the 'Kirātārjunīyam Ballade' and Visuals*", *Eikón Imago*.

**6-Raju Kalidos, (2012).**

"Tamil Literary Traditions and their Relevance in the study of Indian Arts", in *Glimpses of Indian History and Art Reflection on the Past, Perspectives for the Future*, Ed. Tiziana Lorenzetti and Fabio Scialpi, Sapienza University of Rome, pp. 58.

**7-Roveda, V. (2003).**

*Khmer mythology: Secrets of Angkor* (4th ed.). Bangkok: River Books.

**8-Singh, M. P. (2002).**

*Encyclopaedia of teaching of history*. Lucknow: Institute for Sustainable Development.

**9- Vettam Mani, (1996).**

*Purāṇic Encyclopaedia*, Delhi: Motilal Banarsidass, 1996, pp. 412.